# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៧ អនក្រ.សសរ

## សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការគ្រប់គ្រងធនធានខ្សាច់

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** :ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងធនធានខ្សាច់ ដែលមានសមាសភាព ដូចខាងក្រោម :

១- តំណាងក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន អនុប្រធាន

៣- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល — សមាជិក

៤- តំណាងក្រសួងបរិស្ថាន — សមាជិក

៥- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក

**ប្រការ២ :** គណៈកម្មការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ច :

-ត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្មបូមខ្សាច់នាំចេញ និងសម្រាប់ការប្រើប្រាស់ក្នុងស្រុក

-ចុះសិក្សា និងកំណត់ទីតាំងដែលត្រូវអនុញ្ញាតឱ្យធ្វើអាជីវកម្មបូមខ្សាច់ឱ្យបានសមស្រប ដើម្បីសម្រួលដល់ផ្លូវនាវាចរណ៍ និងធានាមិនឱ្យមានការប៉ះពាល់ដល់ចរន្តទឹកទន្លេ ដែលជាមូលហេតុនាំឱ្យបាក់ច្រាំងទន្លេ

- សិក្សាអំពីលទ្ធភាពបូមដីទន្លេមេគង្គ ដើម្បីចាក់បំពេញបឹងសម្រាប់អភិវឌ្ឍន៍ក្នុងរាជធានីភ្នំពេញ ដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ដោយត្រូវធ្វើការសម្របសម្រួលឱ្យការបូមដីនេះ ដំណើរការក្នុងទិដ្ឋភាពរួម

-ពិនិត្យ និងលើកយោបល់សុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ដើម្បីលុបចោលនូវអាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មរបស់ក្រុមហ៊ុន ដែលមិនអនុវត្តតាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងធនធានខ្សាច់

- ធ្វើរបាយការណ៍អំពីលទ្ធផលដែលអនុវត្តបាន ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣ :** គណៈកម្មការគ្រប់គ្រងធនធានខ្សាច់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៤ :** គណៈកម្មការគ្រប់គ្រងធនធានខ្សាច់ មានលេខាធិការដ្ឋានមួយជាជំនួយការងារ នៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីជនដូចក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ៥

-ឯកសារ- កាលប្បវត្តិ